KHMER STORY LOVERS
សម្រាប់អ្នកចូលចិត្តអាន និង តម្កើងសិល្បៈអក្សរសាស្ត្រខ្មែរ

## ៥

# អាវុធដ៏សក្តិសិទ្ធ

នៅពេលដែលភ្លើងអគ្គិសនីភ្លឺឡើង. ខ្ញុំស្រែកអំពាវនាវក្នុងចិត្តខ្ញុំ ហៅគ្រប់វត្ថុស័ក្តិសិទ្ធិទាំងឡាយ ដើម្បីមកជួយទប់កាយវិការគ្របកភ្នែកនិងលក្ខណៈនៃមុខរបស់ខ្ញុំកុំឱ្យញោច ឬកុំឱ្យមានចលនាអ្វីខុសអំពីធម្មជាតិរបស់មនុស្សសន្លប់នោះឱ្យសោះ ។ ខ្ញុំប្រហែលជាបានសម្រេចហើយបានជាខ្ញុំឮសម្លេងរបស់ឧក្រិដ្ឋជន "អាប្រុស" និយាយថា ÷

នាងដេកយ៉ាងឆ្ងាញ់ដដែល !

ឧក្រិដ្ឋជន "មីស្រី" ក៏សួរថា ÷

តើខ្ញុំត្រូវចាក់ថ្នាំឱ្យវាភ្ញាក់ឬ ?



ឮពាក្យថាចាក់ថ្នាំ. ឈាមខ្ញុំកញ្ជ្រោលពុះផុសឡើងបីដូចជាទឹកដែលធ្លាក់មកពីលើកំពូលភ្នំច្របល់បែកខ្ចរខ្ចាយនៅក្នុងជ្រោះដូច្នោះ ។

– កុំទាន់អី. "អាប្រុស" និយាយ ។ គួរតែទុកឱ្យមីចាប់ញីនេះភ្ញាក់ឡើងវិញសិន ។ មិនយូរទេ. អានុភាពនៃថ្នាំសណ្តំជិតអស់ហើយ "អាស្រី" ឯងទៅរៀបចំថ្នាំដើម្បីនឹងចាក់ឱ្យវាចុះ ហើយកុំភ្លេចភ័ស្តុភាដែលយើងត្រូវបរិភោគតាមផ្លូវណា !

– ទុកចិត្តលើខ្ញុំចុះ. "មីស្រី" ឆ្លើយតប ។

– បើអ៊ីចឹង "អាស្រី" ឯងចុះទៅឯក្រោមរៀបចំកិច្ចចាំបាច់ចុះ ។ រួចទុកខ្ញុំឱ្យនៅតែពីរនាក់មីចាបញីនេះសិន. ដូចដែលខ្ញុំធ្លាប់ធ្វើពីដើមរៀងមក. មិនថាអ៊ីចឹង ?

ទឹកមុខ "មីស្រី" ហាក់ជាសម្តែងការមិនពេញចិត្ត ។

– បងផ្ញើកឯងគួរឈប់ប្រព្រឹត្តដូច្នេះទៅ ! ព្រោះស្រីនេះស្អាតល្អជាទីបំផុត ហើយបើតាមមើលប្រហែលជាក្រពុំព្រហ្មចារីទៀតផង បងផ្ញើកឯងប្រយ័ត្នខ្លួន ។ ពីដើមខ្ញុំមិនថាទេ ពីព្រោះពីដើមយើងចាប់បានតែស្រីពេស្យា ឬស្រីដែលបានខូចខ្លួនប្រាណទៅហើយ ដើម្បីយកទៅឱ្យ "ចៅហ្វាយ" យើងធ្វើការរកស៊ីលក់ដូរតទៅទៀត ។

ក្នុងករណីនោះបងឯងអាចធ្វើអ្វីក៏បានដែរ ពីព្រោះផ្លូវនោះមានគេដើរស្រាប់. គេដើរបន្តពីក្រោយមួយពាន់ដង ក៏គ្មានអ្វីចាប់ភ្លឹកដែរ ... ក៏ប៉ុន្តែមីចាបញីនេះវាជារឿងផ្សេង មិនដូចពួកចាបញីពីមុនៗ នោះទេ ។ គឺជាចាបញីក្រពុំបរិសុទ្ធហើយការដែលដឹងថាក្រពុំបរិសុទ្ធមែននោះ. "ចៅហ្វាយ" ប្រុសយើងដែលនៅឯដែននាយឯណោះ នឹងឱ្យរង្វាន់យ៉ាងច្រើនម៉េចក៏បងផ្លែកមិនគិតអំពីរឿងនេះផង ?

បុរសឈ្មោះផ្លែក ក៏បែរមកសម្លឹងមុខសហការិនីរបស់ខ្លួន ស្ទើរហុតឈាមស៊ីសាច់. ហើយកំហែងថា ÷

– កាលពីដើមខ្ញុំធ្វើយ៉ាងណាឥឡូវខ្ញុំត្រូវតែធ្វើយ៉ាងនោះ តើសមត្ថភាពប្រហែលខ្ញុំ ថ្ងៃណា. ខែណា. ឆ្នាំ. សតវត្សណា. ខ្ញុំនឹងបានពើបប្រទះនូវនារីព្រហ្មចារិនី មានវណ្ណៈនឹងពូជត្រកូលល្អយ៉ាងដូច្នេះបាន ? ឱកាសហុចឱ្យហើយខ្ញុំត្រូវតែ ... មិនថាអ៊ីចឹង ? ហើយទោះបីយ៉ាងណាក្តី "អាស្រី" ឯងកុំព្រួយចិត្តថាបងលះបង់ "អាស្រី" ឯងចោល. គឺគ្មានទាល់តែសោះ ។ នេះគឺជាការសប្បាយ នេះគឺជាការជិះក្របីចម្លងភក់. គឺជាក្របីមាស. ក្របីទិព្វក្របីសួគ៌ា...

បុរសឈ្មោះផ្លែក ច្រានស្ត្រីគូសន្ទនានេះចេញទៅក្រៅ ហើយបិទ



ទ្វារគ្រឹប ! ក្រោយពីកំហែង "មីស្រី" នេះថា ÷

– កាលណាខ្ញុំធ្វើការមិនទាន់ហើយ ឬខ្ញុំមិនបើកទ្វារឱ្យចូលទេ "អាស្រី" ឯងគ្មានសិទ្ធិ អ្វីចូលក្នុងបន្ទប់ខ្ញុំជាដាច់ខាត ។ អើ ! អាស្រីឯងក៏ដឹងដែរ ថាទ្វារនេះគ្មានសោទេ ព្រោះវាចាស់ហើយនឹងខូចអស់ទៅហើយ ហើយយើងយល់ថាវាគ្មានការអ្វីចាំបាច់នឹងធ្វើសោថ្មីសោះ ព្រោះមនុស្សដែលសន្លប់ដោយសារថ្នាំ មានកម្លាំងអ្វីនឹងរត់ទៅទីណាកើត ?

សេចក្តីភ័យតក់ស្លុតរបស់ខ្ញុំដូចដែលខ្ញុំបានគិតទុកនោះ បានមកដល់មែន ។ ថ្វីត្បិតតែខ្ញុំឥតបើកនេត្រាក៏ដោយ. ខ្ញុំក៏អាចយល់បានថា "អាប្រុស" នេះនៅ ក្នុងបន្ទប់កំពុងសម្លឹងរាងកាយខ្ញុំឥតដាក់ភ្នែកឡើយ ។ ខ្ញុំទាយបានថាវាមើលខ្ញុំ ពីលើចុះទៅក្រោមពីក្រោមឡើងទៅលើ. ជាច្រើនត្រឡប់ជាច្រើនសា ... វាដើរមកក្បែរខ្ញុំ ហើយវាពោលតិចៗ ថា ÷

– ឱ នារីអីក៏ស្អាតម្ល៉េះ ? ស្អាតម្ល៉េះ ? ខ្ញុំមិនដែលឃើញសោះក្នុងលោកនេះ. រង្វង់ភក្ត្រល្អដូចកិន្នរ. កល្អបីដូចពេរអង្រ្គាសុដនដូចជ្រលងសេកមាស. ចង្កេះល្អបីដូចទេពធីតា. ត្រគាកដូចក្អម. កំភួនជើង

ល្អបីដូចជាសសរថ្មើមថ្ម ...

ខ្ញុំឮសូរដង្ហើមរបស់វាដក មកប៉ះនឹងមុខខ្ញុំ. វាកំពុងតែឈ្ងោកមើលមុខខ្ញុំ ។ រួចវាថើប ហើយវាយកដៃទាំងពីររបស់វាមកច្របាច់សុដនរបស់ខ្ញុំ ។ ឱកាសមកដល់ហើយឬ ? តើខ្ញុំត្រូវប្រើអាវុធដែលនៅនឹងដៃខ្ញុំឬ ? ...

ទេ ! មិនទាន់បានទេ ! ពីព្រោះឧក្រិដ្ឋជនពុំទាន់ស្ថិតនៅក្នុងជំហរមួយ ដែលខ្ញុំអាចប្រើអាវុធនេះបានសោះ ។ វាបន្តការបបោសអង្អែលតទៅទៀត ហើយដៃរបស់វាលូកដល់បុប្ផសំខាន់របស់ខ្ញុំដែលស្ថិតនៅឯចន្លោះភ្លៅ ។ ខ្ញុំស្ទើរតែស្រែក ប៉ុន្តែខ្ញុំខំទប់អារម្មណ៍របស់ខ្ញុំកុំឱ្យកម្រើករំជើបរំជួល ហើយខ្ញុំជឿជាក់ថា ក្នុងចលនាដែលវានឹងធ្វើក្រោយៗ នេះអាចនឹងហុចស្ថានភាពល្អដល់ខ្ញុំ ដើម្បីប្រើអាវុធរបស់ខ្ញុំ ។ ខ្ញុំធ្វើឫកជាប្រែខ្លួនទៅម្ខាង ហើយខ្ញុំដកដង្ហើមធំ ហាក់បីដូចជាទើបនឹងស្វាងពីថ្នាំសណ្ដំដែលវាដាក់ឱ្យខ្ញុំដូច្នោះ ។ ខ្ញុំធ្វើជាបើកភ្នែកឡើងឡង់រួចខ្ញុំសួរថា ÷

– យី ! ចុះកន្លែងនេះជាកន្លែងណា ?

ស្ទើនឹងសំណួរ ខ្ញុំក៏ក្រោកអង្គុយ ហើយក្នុងស្ថានភាពរបស់ខ្ញុំ



ដូច្នេះ "អាប្រុស" នោះក៏ថយក្រោកពីរជំហានដើម្បីទុកឱ្យការភ័ន្តភាំងរបស់ខ្ញុំនេះ កន្លងហួសទៅសិនទើបវាបន្តឧក្រិដ្ឋកម្មក្នុងវិស័យស្នេហារបស់វាទៀត ។ គឺក្នុងស្ថានភាពនេះហើយ ដែលខ្ញុំអាចប្រើអាវុធរបស់ខ្ញុំបាន ។

ឈរឆ្ងាយពីខ្ញុំប្រហែលជាមួយម៉ែត្រកន្លះ ខ្ញុំក៏រលាស់ដៃស្ដាំយ៉ាងខ្លាំង ហើយកាលបើចលនានេះកន្លងទៅ. សម្រែកមួយយ៉ាងខ្លាំងក៏បន្លឺឡើងស្ទើរបែកបន្ទប់ ÷ អូយ ! ...

– ម្រេច ! ម្រេច ! ម្រេចចូលភ្នែកអញ ! អៃយ៉ូយ ! អៃយ៉ូយ ! "មីស្រី" ជួយអញផង. ម្រេចចូលភ្នែកអញហើយ ! ម្រេចចូលភ្នែកអញហើយ !

ស្ទុះមករកខ្ញុំ ដែលតាមពិតខ្ញុំលោតចុះពីលើគ្រែរួចហើយនោះ "អាប្រុស" ក៏យកដៃម្ខាងដែលនៅសល់ វាវលើពូកដោយបើកម្រាមឡើង ប្រាថ្នាច្របាច់ កខ្ញុំដោយកំហឹង ប៉ុន្តែលុះពុំឃើញ. កំហឹងរបស់វាក៏ផ្ទុះបីដូចភ្នំភ្លើង ÷

– មីចាបញី ! អញ ! អញសុភាពណាស់ បើសិនណាមីចាបញីឯងយល់រឿង ហើយសុខចិត្តធ្វើតាមបំណងរបស់អញ ... –

— អាតិរិច្ឆាន! អាតិរិច្ឆាន! ខ្ញុំស្រែកជេរ ។

— ហងរត់មិនរួចពីដៃអញទេ ! ទីនេះនៅឆ្ងាយដាច់ស្រយាល គ្មាននរណាឮឡើយ! (ឧក្រិដ្ឋជនកុហក់ខ្ញុំ)

ក្នុងកាលៈទេសៈតែមួយនេះខ្ញុំរត់សំដៅមាត់ទ្វារ. ក៏ប៉ុន្តែឧក្រិដ្ឋជនវិជ្ជាជីវៈ ដែលមានការពិសោធន៍ច្បាស់ណាស់ ក៏ថយខ្លួនទៅឯមាត់ទ្វារនេះមុន ដើម្បីបង្ខាំងកុំឱ្យ "ចាបញីរបស់ខ្លួនរត់រួច" ។ ដៃម្ខាងខ្ទប់ភ្នែកទាំងពីរ ដៃម្ខាងដែលនៅសល់ "អាប្រុស" នៅឈរបង់ជំទែងនៅកន្លែងទ្វារចេញ ÷

— ឥតប្រយោជន៍ទេ មីចាបញី ! កុំចង់លេងបូនសន្ទឹកជាមួយអញ ! អញដើរច្រើននគរហើយហង ... បន្តិចទៀតកាលណាភ្នែករបស់អញបានស្រួល លែងឈឺផ្សាអញនឹងឱ្យហងស្គាល់នូវសេចក្ដីទុក្ខមួយ ! អញឱ្យហងសប្បាយជាមួយអញ ២០ដង ហើយចាំមើលស្អែកព្រឹកតើហងដើររួចទេ ? ហងនឹងបាក់លោងដូចដង្កូវពុំខាន ! ហងនឹងស្រែកថ្ងូរ. ស្រែករកព្រះកាមទេពឱ្យជួយហង រហូតដល់សន្លប់ ...

— អាតិរិច្ឆាន! អាតិរិច្ឆាន! ប៉ូលិសនឹងនាំពួកឯងទៅ ហើយអា



ឯងនឹងស្គាល់បាតគុកអស់មួយជីវិត! ខ្ញុំស្រែកដោយកំហឹង ។

— ប៉ូលិស ! ប៉ូលិសឯណាមកដល់ទីនេះ ! ប៉ូលិសពុំមែនមានភ្នែកទិព្វត្រចៀកទិព្វនោះទេ ! ហើយប្រសិនបើប៉ូលិសចូលមកដល់ទីនេះមែន. មីចាបញី ! កុំនឹកស្មានថាអញអាផ្លេក ជើងឆ្លងកាត់ពីដែននាយមក មិនមែនឱ្យប៉ូលិសចាប់អញច្រកចុងងាយៗ នោះទេ. អញមានកាំភ្លើងការពារខ្លួនអញដែរ. មិនថាអ៊ីចឹងមីចាបញី ? ហើយមុននឹងចូលមកដល់ទីនេះ. មីចាបញីឯងក៏ដឹងដែរថា មានឧបសគ្គប៉ុន្មានកន្លែង ?

ស្របពេលជាមួយគ្នានោះ. ទ្វារបន្ទប់នេះក៏របើកឃ្លាំងឡើង ហើយលេចធ្លោរនូវ "មីស្រី" ចូលមក ។

— ស្អី ? កើតមានរឿងស្អី ? ហាៈ ម៉េចអ៊ីចឹង ? មីចាបញីនេះមានកម្លាំងហើយ ?

— កុំទៅរវល់នឹងវាអី ! ជួយមើលភ្នែកអញផង. អញឈឺណាស់. ហ៎ ... រហ័សឡើងមើលភ្នែកអញផង!

— មិនបានទេបងផ្លេក ខ្ញុំឈរចាំត្រង់មាត់ទ្វារនេះ (នាងនិយាយផងបិទទ្វារវិញផង) បងផ្លេកឯងកើតអីភ្នែកហ្នឹង ?

– ម្រេច ! ម្រេច. ម្រេច ! កុំសួរហេតុផលច្រើន !

– មិនបានទេបងផ្លេក. បងឯងដើរទៅបន្ទប់ទឹកខ្លួនឯងចុះ ខ្ញុំនៅឈរចាំទីនេះ. បើមិនដូច្នោះទេ មីចាបញីអាចនឹងរត់ចេញពីវិមានរបស់យើងបានហើយ រឿងរ៉ាវដែលនឹងកើតឡើងនោះពុំមែនជាល្អសំរាប់យើងទាំងពីរនាក់ឡើយ. មិនថាអ៊ីចឹង ? លាងមុខឱ្យរហ័សទៅខ្ញុំមានសាវ៉ាំងនិងថ្នាំចាំចាត់ការស្រេចហើយ ។

ឮពាក្យសាវ៉ាំងហើយនឹងថ្នាំ ខ្ញុំតក់ស្លុតភ្លាម ។ ថ្នាំនេះពុំមែនជាថ្នាំលើកកម្លាំងឡើយ ខ្ញុំជឿជាក់ថាជាថ្នាំម្ជុលទី២ ដែលមានមហិទ្ធិឫទ្ធិជាថ្នាំសណ្ដំ ដែលដាក់លាយក្នុងគ្រាប់ស្ករពីលើកមុន២០ដង ។ គឺជាការពិតណាស់ថា ចាក់ថ្នាំសណ្ដំលើកទីពីរនេះ ដើម្បីឱ្យខ្ញុំគេងសន្ធឹងសន្ធៃនៅក្នុងឡានពេទ្យ រួចវានឹងដឹកខ្ញុំទៅកាន់គោលដៅឆ្ងាយ ... តើទៅដល់ទីណាទៅ ?

ខ្ញុំត្រូវតែខំរកវិធីដោះស្រាយឱ្យបានឆាប់រហ័សបំផុត បើមិនដូច្នោះទេ ជីវិតដ៏ឆ្ការដូចខ្សែអម្បោះរបស់ខ្ញុំនឹងដាច់ហើយ ... សំដីរបស់ឧក្រិដ្ឋជនខ្ញុំឮជាក់ច្បាស់ណាស់ថា ការចាប់រូបខ្ញុំមកនេះពុំមែនមានគោលបំណងអ្វីក្រៅពីយកខ្ញុំទៅលក់ឱ្យ "ចៅហ្វាយ" ដើម្បីធ្វើ



ជាទាសីរពេស្យានៅឯ ... ឯណាទៅ ? ពុំមែននៅក្នុងប្រទេសកម្ពុជានេះទេ ដែលជាប្រទេសកំណើតរបស់ខ្ញុំ គឺនៅឯខាងដែននាយឯណោះ ...

"មីស្រី" ស្រែកប្រាប់អាប្រុស. ភ្លាមដែលវាកំពុងតែលុបមុខ ÷

– រហ័សឡើង ! រហ័សឡើងបងផ្លេក ! ខ្ញុំមើលមីចាបញីនេះកំពុងសម្ដែងឫទ្ធិសម្បើមហើយវាប្រុងនឹងរត់ចេញ ។"

ផ្លេកហាក់ចេញពីបន្ទប់ទឹកមកវិញ ក៏ប៉ុន្តែដៃនៅតែក្ដោបភ្នែកដដែល ÷

– អៃយូយ ! ភ្នែកអញមើលអ្វីពុំឃើញទេ ! លុបមុខហើយក៏ឥតប្រយោជន៍ទៀត ! តើឱ្យអញធ្វើយ៉ាងម៉េច ?

– បងផ្លេកឯងបែរមកខាងកើត ហើយដើរទៅមុខមីចាបញីវានៅត្រង់នោះឯង ។

ផ្លេកគោរពតាម ដៃម្ខាងខ្ទប់ភ្នែក ដៃម្ខាងរាវស្រវាចាប់ "ចាបញី" របស់ខ្លួន ។ ខ្ញុំគេចទៅម្ខាង ។

ការគេចការដេញតាម បញ្ជារបស់ "មីស្រី" ឧក្រិដ្ឋនេះឱ្យមនុស្សខ្វាក់តាមក្របួចខ្ញុំ មានភាពល្អមើលណាស់ ប្រសិនបើគេយកទៅ

បញ្ចាំងជាភាពយន្ត ។

ឧក្រិដ្ឋជនហក់ចូលមកខ្ញុំគេចចេញ ។ ខ្ញុំគេចចេញវាហក់ចូល ។ ចលនាដេញគ្នាបីដូចរស្មីអគ្គិសនីដែលច្របូកច្របល់ដូច្នោះ ។ ខ្ញុំគេចរកព្រះអាយុវាហក់ចូលប្រាថ្នាចាប់ខ្ញុំ ។ ឧក្រិដ្ឋជនដែលខ្វាក់ភ្នែកទាំងពីរទៅហើយនោះព្រោះវាមើលពុំឃើញ. វាបានដឹងវត្តមានរបស់ខ្ញុំនៅត្រង់ជ្រូងនេះឬត្រង់ជ្រុងនោះដោយសារ "មីស្រី" ជាអ្នកប្រាប់ ។ គឺល្បែងបិទពួនស្មោះ. បីដូចជាគេលេងស្វាដណ្តើមទីដែលប្រព្រឹត្តទៅក្នុងបន្ទប់ដ៏ចង្អៀតមួយមានគ្រែទៀតផង ។

គឺជាយុទ្ធកម្មដ៏សាហាវ រវាងបុរសនិងស្ត្រីបីដូចនាងមេខលាដែលប្រយុទ្ធជាមួយយក្ស ដែលចង់ដណ្តើមយកកែវមនោហរ៍ពីនាងដូច្នោះ ... ខ្ញុំគ្មានសំណាងគេចទៅខាងកើតទេ ពីព្រោះ "មីស្រី" នៅប្រចាំទីនោះ ។ តែមួយភ្លែតប៉ុណ្ណោះ ក្រោយពីរត់យកព្រះអាយុដ៏អស់សង្ឃឹមនោះ ។ ខ្ញុំក៏ភ្លាត់ជើងដួល. ហើយឧក្រិដ្ឋជនដែលជាមនុស្សវិជ្ជាជីវៈស្រាប់នោះក៏ហក់មកហើយក៏ចាប់ខ្ញុំជាប់ វាសង្កត់ កខ្ញុំផ្ទាប់នឹងកម្រាលឥដ្ឋ ហើយ "មីស្រី" នោះក៏បោលមកហើយអង្គុយលើពោះខ្ញុំ ។ ខ្ញុំមិនទាន់ធ្វើចលនារើបម្រះអ្វីផង ស្រាប់តែមានម្ជុល



មួយចាក់ចូលក្នុងត្រគាករបស់ខ្ញុំស្រេច បណ្តាលឱ្យខ្ញុំមានសេចក្តីឈឺចាប់ជាខ្លាំង ពីព្រោះ "មីស្រី" ឧក្រិដ្ឋបានបាញ់ថ្នាំចូលក្នុងសាច់ខ្ញុំអស់ថ្នាំពីបំពង់ ។

– តែប៉ុណ្ណេះ. ស្រេចយ៉ាងហើយមីចាបញី ... (ហើយនាងនិយាយទៅកាន់សហការីរបស់នាង) បងផ្លេក ស្រេចហើយ ...

ប៉ុន្តែផ្លេក ... មិនទាន់លែងដៃអំពីកខ្ញុំនៅឡើយទេ. រួចវានិយាយពាក្យ ដ៏ទុឃិសថា ÷

– តែបន្តិចទៀត. មីចាបញីឯងនឹងគេងស្រមុកឃ្វើយនៅក្នុងឡានទេព្យរបស់យើង ... ចម្ងាយផ្លូវដែលយើងត្រូវធ្វើដំណើរវែងឆ្ងាយណាស់ ... ហើយនៅពេលនោះ មីចាបញីឯងនឹងបានទទួលសេចក្តីសុខសប្បាយជាកំពូល ... ខ្ញុំនឹងលែលកឱ្យមីចាបញីឯងបានស្គាល់ឋានសួគ៌ពីនេះរហូតទៅដល់ព្រំដែន ២០ដង. ហើយចាំមើលមើល៍ ថាតើមីចាបញីឯង ហើយនឹងលលកខ្មោច អ្នកណាឈ្នះអ្នកណា ?

ខ្ញុំគ្មានបានឮសំដីអ្វីតទៅទៀតឡើយ ។ ត្រចៀករបស់ខ្ញុំហ៊ឹងអស់ ។ ភ្នែករបស់ខ្ញុំស្រវាំងមើលអ្វីលែងឃើញ ហើយបន្ទប់ទាំងមូល

ហាក់បីដូចរវើរាំចង្វាក់ទីសដូច្នោះ ។ បន្តិចម្តង១ ដួងវិញ្ញាណខ្ញុំទ្រុឌទ្រោមទៅ ...

# ៦

# នារីសំពត់ពណ៌ស្វាទុំ

វិចិត្រអង្គុយនៅពីមុខផ្ទាំងគំនូររបស់អ្នក ដោយចិត្តកន្ទះរាជាខ្លាំង ។ តាំងពីពេលនោះមកដល់ឥឡូវនេះ វាជាការហួសចិត្តទៅហើយថា ហេតុអ្វីបានជាកន្ទ្ទីរពុំទាន់វិលត្រឡប់មកផ្ទះវិញ ? ឬមួយក៏នាងមកវិញរួចទៅហើយ ? ប៉ុន្តែជាការធម្មតាទេ ដោយឋានៈអ្នកជាសង្សាររបស់គេនៅឡើយ. អ្នកមានការអៀនខ្មាសខ្លាំងណាស់ហើយពុំចង់សួរអនាគតបងថ្លៃស្រីនេះ តាមទូរស័ព្ទឱ្យបានញឹកញាប់ឡើយ ។ អ្នកនឹកដល់សំណោងរបស់អ្នកដែលឪពុកម្តាយ របស់អ្នកបានទៅសម្រាន្តនៅឯផ្ទះបុរាណគាត់នោះ. កុំអីអ្នកក៏មានការពិបាកណាស់ ដើម្បីទូរស័ព្ទទាក់ទងជាញឹកញយ. ដោយហេតុថាទូរស័ព្ទ

នេះនៅក្បែរបន្ទប់សម្រាន្តរបស់គាត់. អ្នកងើយមើលទៅនាឡិការ ប៉ោល ÷ ម៉ោង ១២និង៥នាទី ... អ្នកក៏រវៃលេខទូរស័ព្ទ ហៅអនាគតបងថ្លៃរបស់អ្នក ។ នៅពេលដែលគេលើកដៃទូរស័ព្ទឯចុងខ្សែម្ខាងហើយ. ដោយមានជំនឿជឿជាក់ថា កន្ធីសង្សាររបស់អ្នកវិលត្រឡប់មកផ្ទះវិញហើយនោះអ្នកក៏និយាយផ្ទួងថា ÷

– អូនកន្ធី. មែនទេ ?

– អ្នកណាហ្នឹង ? វិចិត្របួ ? មិនមែនទេ. កន្ធីរបស់វិចិត្រឯងមិនទាន់ត្រឡប់មកវិញឡើយ. ធ្វើឱ្យខ្ញុំភ័យសម្បើមណាស់ ! ខ្ញុំឈប់កែកិច្ចការសិស្សហើយ. ខ្ញុំកំពុងអង្គុយទន្ទឹងផ្លូវ ដូចដែលម្តាយទន្ទឹងកូនដូច្នោះ ...

– បើដូច្នេះបានន័យថា ... បានន័យថាកន្ធីមានគ្រោះថ្នាក់មែនទេបងស្រី ?

– តាមខ្ញុំយល់មានតែច្រកនេះឯងដែលយើង ... អាចសង្ស័យបាន. ពីព្រោះថាកន្ធីទោះបីទៅគេងផ្ទះមិត្តភក្តិស្រីឯណាក្តី. ឬទៅគេងផ្ទះអ៊ំក្តី. ដែលតាមពិតរបៀបហ្នឹងកម្រមានណាស់ហើយប្រសិនបើមានវិញ. កន្ធីសុទ្ធតែប្រាប់ខ្ញុំជាមុន ។



សំដីរបស់អ្នកគ្រូ ដែលជាអនាគតបងថ្លៃនេះបានធ្វើឱ្យវិចិត្រនឹកឃើញភ្លាម ÷

– បងស្រី. កាលដែលកន្ធីទៅមើលកុននោះ តើនាងស្លៀកពាក់សំពត់អាវពណ៌អ្វីខ្លះ ?

– ម៉េចបានជាវិចិត្រសួរបងដូច្នេះ ? កាលដំបូងនាងមកផ្ទះហើយមេឃក្តៅពេក នាងក៏ផ្លាស់សម្លៀកបំពាក់ពណ៌ខៀវនោះចេញព្រោះវាក្រាស់ពេក ។ រួចនាងស្លៀកពាក់សំពត់អាវពណ៌ស្វាទុំ ដែលជាក្រណាត់ Popeline Swiss ។ គឺអាវពណ៌ស្វាទុំណាវិចិត្រ ...

– អាវពណ៌ស្វាទុំ ! ព្រះអើយ. បើអ៊ីចឹងបានន័យថាខ្ញុំ ... ខ្ញុំ ... ខ្ញុំបានជួបនឹងកន្ធីនៅឯ ...

– នៅឯណា ?

– នៅឯផ្លូវច្រកងងឹតមួយ ។ ជាមួយនឹងមនុស្សពីរនាក់ទៀតគឺប្រុសម្នាក់ស្រីម្នាក់ ។ ក៏ប៉ុន្តែដោយខ្ញុំឃើញកន្ធីស្លៀកពាក់ខោអាវពណ៌ខៀវមុននឹងចេញអំពីផ្ទះខ្ញុំទៅនោះ ខ្ញុំក៏ពុំសូវជាយកចិត្តទុកដាក់ចាប់ភ្លឹកប៉ុន្មានឡើយចំពោះ នារីម្នាក់ទៀតដែលមានសម្លៀកបំពាក់ពណ៌ស្វាទុំនេះឯង ។ ខ្ញុំបានបរឡានកាត់តាមនោះ ហើយចោលភ្នែក

មួយភ្លែតតែប៉ុណ្ណោះ. រួចមកខ្ញុំគ្រាន់តែនឹកក្នុងចិត្តថាខ្វះអ្វីមនុស្ស ដែលមានរូបរាងដូចគ្នាមួយគំនរនោះ ។ ក៏ប៉ុន្តែសម្លៀកបំពាក់ពណ៌ស្វាទុំនោះខ្ញុំរលាស់ជំនឿយ៉ាងឆាប់រហ័សថា នារីដែលនៅឈរជាមួយនឹងបុរសនិងស្ត្រីនោះពុំមែនជាកន្និរីឡើយ ...

សេចក្ដីស្ងប់ស្ងៀមបានកើតឡើងមួយរយៈកាល នៃគូសន្ទនាទាំងសងខាងនេះ មើលទំនងប្រហែលជាគេកំពុងរិះគិតទេដឹង ? នៅទីបំផុត ...

– បើដូច្នេះ តាមគំនិតវិចិត្រឯងថានារីដែលវិចិត្រឯងឃើញនៅឯច្រកងងឹតនោះគឺជាកន្និរីមែនទេ ?

– ឥឡូវខ្ញុំស្ទើរតែអស់សង្ស័យហើយ ។ នារីដែលខ្ញុំឃើញនោះគឺជាកន្និរី ... តើកន្និរីទៅកន្លែងច្រកងងឹតនោះជាមួយនឹងមនុស្សពីរនាក់ធ្វើអ្វី ?

– អ្នកណាដឹងបានហ៎ ? ជួនកាលប្រហែលជាកន្និរីដើរជាមួយមិត្តភក្ដិរបស់ខ្លួនដែលទើបមានស្គាល់ទេដឹង ? ឬ ... ពិបាកស្មានណាស់វិចិត្រខ្ញុំក៏មិនអាចនឹងដឹងបានដែរ ។ ក៏ប៉ុន្តែទោះបីក្នុងលក្ខណៈយ៉ាងណាក៏ដោយ. ខ្ញុំជឿជាក់ថា កន្និរីប្អូនស្រីខ្ញុំសុទ្ធតែឱ្យដំណឹងមក



ខ្ញុំជានិច្ច មិនមែនទុកឱ្យខ្ញុំស្ថិតនៅក្នុងសេចក្ដីតក់ស្លុតនិងភ័យយ៉ាងដូច្នេះទេ ។

ស្ងាត់មួយភ្លែតទំនងជារិះគិតទៀត ។ វិចិត្រក៏ចាប់ផ្ដើមនិយាយឡើងទៀតថា ÷

– បើអ៊ីចឹង មានតែវិធីមួយគឺយើងត្រូវតែទៅរកផ្លូវច្រកងងឹតនោះវិញ ។ សូមបងស្រីចាំខ្ញុំនៅឯមុខផ្ទះ ខ្ញុំនឹងបើកឡានទៅទទួលបងស្រីទៅជាមួយដែរ ។

– ភ្លាម. វិចិត្រខ្ញុំចាំជានិច្ច ។

ការសន្ទនាតាមទូរស័ព្ទដ៏ដាច់ត្រឹមនេះ ។ ប្រមាណជា៥នាទីក្រោយរថយន្តរបស់វិចិត្រក៏បានមកឈប់នៅមុខផ្ទះរបស់អ្នកគ្រូ ។ អ្នកគ្រូក៏ឡើងឡាន. ហើយអាជានេយ្យយន្តនេះក៏បោលទៅមុខឥតសំចៃ ។ ម៉ោង ១២ និង ២០នាទី យើងរំលឹកឃើញគឺនៅម៉ោងនេះឯង ដែលកញ្ញាកន្និរីបានរវៃទូរស័ព្ទក្នុងវិមានឧក្រិដ្ឋ ដើម្បីហៅបងស្រីរួច ហៅសង្សារគឺវិចិត្រនេះឯង ។ ព្រោះតែហេតុនេះឯងបានទូរស័ព្ទនោះរោទ៍ឥតមានអ្នកណាឆ្លើយសោះ ។ គឺបានន័យថាឃ្លាងគ្នានៅតាមដងវិថីឯណោះ. រថយន្តរបស់វិចិត្របោលដូចព្យុះ

សង្ឃរាសំដៅទៅតាមផ្លូវប្រជាធិបតេយ្យ ។ គួរកត់សំគាល់ថា ក្នុងពេលរឿងនេះកើតឡើង. កាលណោះប្រទេសរបស់យើងស្ថិតនៅក្នុងសន្តិសុខនៅឡើយ ។ អាជានេយ្យយន្តបោលទៅមុខ. ហើយក្នុងមួយរំពេចនោះ ស្រាប់តែវិចិត្រស្ទាក់ស្ទើរពុំដឹងជាបើកទៅតាមផ្លូវណាទៀត ។

– បងស្រីខ្ញុំពុំបានយកចិត្តទុកដាក់ថាជាច្រកណាមួយទេ ដែលខ្ញុំបានបរកាត់ពីមុនដោយជួបកន្ទីរនោះ. បងស្រីក៏ជ្រាបដែរ ហើយថាផ្លូវបែកចេញពី មហាវិថីប្រជាធិបតេយ្យនេះមានច្រើនណាស់ ។ តើផ្លូវណាមួយ ?

អ្នកគ្រូដកដង្ហើមធំ ÷

– បើវិចិត្រមិនដឹងផង តើឱ្យខ្ញុំដឹងយ៉ាងម៉េចទៅហ៎ ? អ្នកគ្រូនិយាយដោយសម្លេងចង់អស់សង្ឃឹម ។

ក្រោយពីបើកនិងបត់បែន ៥-៦សា. វិចិត្រហាក់ធ្លាក់ទៅក្នុងការស្រយុតស្រយង់ចិត្តមួយ ។ អ្នកស្ពាយខ្លាំងណាស់ពុំគួរធ្វេសប្រហែសហើយពុំគួរថាឥតចាំច្រកចូលសោះ ។ គឺជាផ្លូវដីក្រហែងក្រហូង ។ ក៏ប៉ុន្តែមានផ្លូវដីក្រហែងក្រហូងដល់ទៅ ១០ ឬ ២០ ឯ



ណោះនៅតាមបណ្តោយមហាវិថីប្រជាធិបតេយ្យតើផ្លូវណាមួយ ?

ពេលវេលាកន្លងទៅមុខសន្សឹមៗ ក៏ប៉ុន្តែចំពោះវិចិត្រ និងអ្នកគ្រូវេខា ពេលវេលានេះលឿនហោះដូចព្រួញ ។ ក្រោយពីស្ងៀមមួយសន្ទុះ. ហើយក្នុងសួរស័ព្ទរថយន្តដែលលាន់ខ្ទ័រខ្ទានេះ. វិចិត្រក៏អារកាត់ៗ ថា ÷

– ខ្ញុំគិតថាគួរបងស្រីអញ្ជើញទៅកាន់បកប៉ូលីសមុន. ហើយជំរាបគេហួរហែអំពីរឿងបាត់ខ្លួនរបស់កន្ទីរនេះ រួចសូមឱ្យប៉ូលីសចេញចាត់វិធានការយ៉ាងណា ដើម្បីឆែកឆេរនិងឃាត់គ្រប់រថយន្តទាំងអស់ដែលចេញផុតពីទីក្រុងនេះ ។ ការធ្វើដូច្នេះវាប្រសើរជាជាងមិនធ្វើអ្វីទាំងអស់នោះដែរ ។ ឧបមាថា ឧក្រិដ្ឋជនដែលចាប់រូបនាងមានបំណងនឹងនាំចេញទៅក្រៅនោះពិតរត់ពុំរួចពីដៃប៉ូលីសឡើយ ។ ឧបមាថា ឧក្រិដ្ឋជនបានចាប់នាងដើម្បីសេចក្តី សប្បាយរបស់វានៅក្នុងទីក្រុង. ការដែលធ្វើដូច្នេះពុំមែនជាឥតប្រយោជន៍ ឡើយចំពោះប៉ូលីស ។ ថាដូច្នេះហើយរថយន្តក៏ឈប់ងក់ មុខនិគមស្នងការដ្ឋានទួលទំពូង ។ អ្នកគ្រូក៏ចុះ. ឡានក៏ទៅមុខទៀត ។

រថយន្តរបស់វិចិត្របោល ទៅមុខឥតគោលដៅហើយចេញចូល

គ្រប់ច្រកផ្លូវ ...

តើវិចិត្ររកច្រកនិងវិមានដ៏អាថិកំបាំង ដែលអ្នកស្រមៃក្នុងចិត្ត ថា កន្ទីរបស់អ្នកដែលស្លៀកពាក់ពណ៌ក្រហម ឬពណ៌ស្វាទុំនៅទី នោះឃើញដែរឬទេ ?

## ៧

## សំណាងពីអតីតកាល

នៅពេលដែលខ្ញុំ កំពុងតែទ្រុឌទ្រោមក្រោមអានុភាពថ្នាំសណ្ដំ ដែល "មីស្រី" ឧក្រិដ្ឋបានចាក់បញ្ចូលទៅក្នុងសាច់ខ្ញុំនោះ ខ្ញុំខិតខំទប់ស្មារតីខ្ញុំកុំឱ្យស្រយុតស្រយង់ហួសហេតុ ទៅតាមអានុភាពថ្នាំ ។ ក្នុងពេលនោះខ្ញុំបានឮឧក្រិដ្ឋ ជនទាំងពីនាក់នេះកំពុងតែនិយាយឆ្លើយឆ្លងគ្នា ÷

– "អាស្រី" បងពុំអាចទ្រាំទ្រនឹងអាការផ្សារភ្នែកនេះបានទេ ។ មីចាបញីនេះវាជះម្រេចមួយកញ្ចប់ចូលភ្នែកបងទាំងសងខាង. លុបមុខប៉ុណ្ណោះក៏ឥតផ្លូវដែរប្រហែលជាខ្វាក់ផងក៏ពុំដឹង ... ដូច្នេះតើឱ្យគិតយ៉ាងដូចម្ដេចហា ? បានអ្នកណាបើកបរឡានទៅ ? ពីព្រោះពី

ទីនេះទៅដល់បាត់ដំបង ហើយពីបាត់ដំបងទៅដល់អូរជ្រៅ. "អាស្រី" គិតមើលថាតើត្រូវចំណាយពេលប៉ុន្មានម៉ោង ហើយតើបងបើកបរយ៉ាងដូចម្ដេចបានបើភ្នែកបងបើកខ្លួនឯងពុំរួចផងនោះ ?

អ៊ីចឹង បងផ្ដែកឯងគិតយ៉ាងណាទៅឥឡូវនេះ ?

បងគិតថាឱ្យ "អាស្រី" ឯងចាក់ថ្នាំ Morphine ឱ្យបងមួយម្ជុល ដើម្បីឱ្យបងដេកសម្រាក. ឯកិច្ចការនេះគួរ "អាស្រី" ឯងប្រគល់ឱ្យអាឆ្កួញម្ដង ដើម្បីឱ្យវាធ្វើការនេះជំនួសបង. មិនថាអ៊ីចឹង "អាស្រី" ?

"មីស្រី" ឧក្រិដ្ឋស្ទាក់ស្ទើរចិត្ត ហើយក៏រលាស់សំនួរថា ៖

ចុះបើកពីទីនេះចេញទៅនោះ បងផ្ដែកឯងគិតយ៉ាងដូចម្ដេចទៅ?

នៅកណ្ដាលក្រុងមិនជាអ្វីទេ "អាស្រី" ឯងចេះបើកឡានស្រាប់ ហើយតើ "អាស្រី" ឯងបើកបរទៅរកផ្ទះអាឆ្កួញវាក៏ធ្លាប់រួមសហប្រតិបត្តិការជាមួយយើងអ៊ីចឹងដែរ. មានអ្វីដែលថាវាប្រកែក ?

បើអ៊ីចឹងយើងគិតចេញដំណើរឥឡូវមែនទេ ? សម្លេង "មីស្រី" សួរ ។

ត្រូវហើយ "អាស្រី" ទម្រាំយើងលើក "មីចាបញី" បញ្ចូលក្នុងឡាន. ទម្រាំ "អាស្រី" ឯងចាក់ថ្នាំ Morphine ឱ្យបងបានដេកលក់.



ពីព្រោះភ្នែករបស់បងពើតចុកចាប់ណាស់. ទំរាំ "អាស្រី" ឯងទៅរកអាឆ្កួញទៀត. ឃើញថាពេលវេលានៅពីមុខយើងខ្លីណាស់ហើយ "ចៅហ្វាយ" របស់យើងនឹងមិនអភ័យទោសឱ្យយើងទេ បើយើងចេះតែបណ្ដែតបណ្ដោយឱ្យយូរថ្ងៃមិនថាអ៊ីចឹង ? ហ៏ឥឡូវចាត់ការភ្លាមទៅ !

វាទាំងពីរនាក់ក៏យកគ្រែស្នែង របស់ពេទ្យចេញមក ហើយលើកខ្ញុំដាក់លើគ្រែស្នែងនេះ ។ ថ្វីត្បិតតែកម្លាំងកាយរបស់ខ្ញុំ ចេះតែទ្រុឌទ្រោមទៅៗ ក៏ដោយ. ក៏កម្លាំងចិត្តនិងមនសិការរបស់ខ្ញុំនៅចងចាំជានិច្ច ។ ដោយសារការប្រឹងទប់នូវអានុភាពនៃថ្នាំនេះ ត្រចៀកខ្ញុំក៏ហ៊ឹងឥតបើប្រៀបបាន ។ ឧក្រិដ្ឋជនពិតជានឹងនាំខ្ញុំឆ្លងដែនទៅកាន់ប្រទេសសៀម ក្នុងគោលបំណងមួយគឺយកខ្ញុំទៅឱ្យធ្វើពេស្យាកម្ម ។ នារីនៃសកលលោកនេះតែងបានជួបគ្រោះថ្នាក់ អកុសលរបៀបនេះជាច្រើនណាស់ ។ នៅតាមប្រទេសខ្លះៗ នៃសកលលោកនេះ. គេចាប់យកស្ត្រីទៅធ្វើ "ជំនួញឋានសួគ៌" ហើយការស៊ុំគ្រលំរបស់អាជ្ញាធរ នៅឯព្រំដែនក៏មានសន្ទឹកសន្ធាប់ណាស់ដែរ ហើយសារពត៌មានក្នុងសកលលោកនេះតែងតែបានចុះផ្សាយអំពីការ បាត់ខ្លួនរបស់ក្រមុំ

បារាំង អារ៉ាប់. ស៊ុយអែត ឥណ្ឌូណេស៊ី ឬអាមេរិកឡាទីន ជាច្រើនក្បាល ...

ទោះបីសព្វថ្ងៃនេះក្ដី "ការរត់ពន្ធស្រី" មានសន្ទឹកសន្ធាប់ណាស់ ...ដូច្នេះ គួរនារីខ្មែរយើងមានសេចក្ដីប្រុងប្រយ័ត្ន ចៀសវាងនូវការដើរម្នាក់ឯង ឬដើរនៅកន្លែងស្ងាត់ដោយពុំគប្បី ហើយម្យ៉ាងទៀតការជឿសំដីរបស់បុរសខ្លះៗ ដែលនាងពុំសូវស្គាល់ច្បាស់ ហើយនាងពុំគប្បីទៅជាមួយនឹងបុរសនេះឯទីដទៃណា ដែលនាងគ្មានអ្វីការពារខ្លួននោះទេ...

ថ្មីត្បិតតែខ្ញុំហៀបនឹងស្រយុតស្រយង់ទៅក្នុងឋិនមិទ្ធ (១) ទៅហើយក៏ ដោយខ្ញុំក៏នៅតែដឹងអំពីចង្វាក់គ្រែស្នែងដែលកំពុងលោតផ្លោតៗ តាមជំហានជើងនៃឧក្រិដ្ឋជនដែលកំពុងតែសែងខ្ញុំចុះជណ្ដើរក្រៅអំពីចលនារលាក់នេះ ខ្ញុំឮសូរសម្លេង "មីស្រី" កំពុងតែបញ្ជា "អាប្រុស" ឱ្យបត់ស្ដាំ ឆ្វេង ឬឱ្យដើរត្រង់ទៅមុខ ។ "អានេះ" ក្លាយមកជាពពៃខ្វាក់ដែរ "មីសេះញី" កំពុងជួយតម្រង់ផ្លូវ ។ នៅពេល

(១) ការងងុយដេក



ដែលគេដាក់ខ្លួនចុះ. ច្រមុះរបស់ខ្ញុំធុំក្លិនថ្នាំលាបថ្មីៗ ។ តាមខ្ញុំយល់គឺជាថ្នាំដែលគេលាបឡានសម្រាប់ដឹកខ្ញុំទៅនរកហើយ. គឺឡានពេទ្យ ។ តាមទំនងមើលវាទើបតែនឹងលាបថ្នាំថ្មីៗ. ពុំដឹងជាមែនឬមិនមែនទេ ... ខ្ញុំហៀបនឹងរលត់ស្មារតីក្នុងការនិទ្រាទៅហើយ. ខ្ញុំឮសូរសម្លេង "អាប្រុស" ប្រាប់ "មីស្រី" ថា ÷

– អញស្ដាយណាស់ ដូចជាមីកន្ទុចឯងដឹងស្រាប់ហើយ ... មីចាបញី នេះមានរូបឆោមស្អាតផុតស្រីទាំងឡាយ ក៏ប៉ុន្តែវាចង្រៃភ្នែកអញនេះចុកចាប់ហួសនិស្ស័យនឹងថ្លែង. កុំអីអញទៅលេងឋាន-សួគ៌ជាមួយនឹងវាដូចដែលបាន សន្យាជាមួយនិងវាអម្បាញ់មិញមុនដែលវាសន្លប់២០ដងយ៉ាងតិច ... មិនអី ទេចាំថ្ងៃត្រង់ដែលអញបានស្បើយក៏បានដែរ. វាមិនទៅណាទេ. វានៅតែក្នុងឡានដូច្នេះឯងហើយជាប់ចំណងទៅទៀត ។

– បានហើយបងផ្ដេកប្រយ័ត្នអាឆ្កួញវាដឹងឮដល់ "ចៅហ្វាយធំ". បងផ្ដេកឯងមុខជារកអំបិលប្រឡាក់គ្មានឡើយ ... កាំបិត. កាំភ្លើង. ឡដុតបន្សុះទាំងរស់. បងផ្ដេកឯងមិនមែនថាមិនដឹងនោះទេ ... បងផ្ដេកឯងអាចបោក "ចៅហ្វាយ" របស់បងឯងបានដោយគាត់

ខឹងមានថ្ងៃនឹងជាមើលមុខបងឯងវិញ. ក៏ប៉ុន្តែប៉ះពាល់ដល់រឿងស្រីមុន "ចៅហ្វាយ" បងអើយសូម្បីតែផែនដីនេះ ប្រេះជាពីរក៏បងឯងពុំបានសេចក្ដីសុខដែរ ... ម្យ៉ាងទៀតបងឯងដឹងស្រាប់ហើយថា នៅឯម្ខាងព្រំដែនយើងឯណោះ. ការបើក "ស្រទាប់ផ្កា" គ្រេបច័ន្ទទឹកឃ្មុំនោះមានតម្លៃច្រើនម៉ឺនបាតណាស់ ... ហើយតាមខ្ញុំដឹងមីចាបញីនេះវានៅក្រពុំបរិសុទ្ធ. មិនដឹងមែនឬមិនមែនឡើយមានតែចៅហ្វាយយើងទេដែលអាចដឹងបាន. ក្រោយពីភ្លក់រួចហើយ ...

បានហើយមីកន្ទួចចាក់ថ្នាំឱ្យអញមក ដើម្បីដេកសំរាកមួយម៉ោងពីរម៉ោងសិន ចៀសវាងកុំឱ្យភ្នែកអញចុកផ្សាពេក ។ បន្ទាប់មកអាស្រីឯងបើកឡានទៅរកអាឆ្លូញឱ្យវាជូនដំណើរម្ដង ។ ចំណែកអញនៅដេកក្បែរមីចាបញីនេះ ហើយអាស្រីឯងរកវិធីដោះស្រាយជាមួយនឹងប៉ូលីសឬអាជ្ញាធរ

ដែលឃាត់ឡានយើងនេះនៅតាមផ្លូវផង ... ថ្នាំ Morphine ដែលអាស្រីឯងចាក់ឱ្យអញ ប្រហែលជាមិនងើបមុន ៣ម៉ោងក្រោយពីបានសម្រាកនោះឡើយ ... ៣ម៉ោងក្រោយភ្នែកអញប្រហែលជានឹងបាត់ផ្សាហើយមីចាបញីនេះក៏បានដឹងខ្លួនដែរ ... ដល់ពេលនោះ



ស្នេហាដែលវាប្រទាក់ក្រឡាត្តា គឺបានសប្បាយណាស់ គេមិនដែលទៅស្នេហាជាមួយមនុស្សម្នាក់ដែលសន្លប់ដូចមីចាបញីនេះទេ. បើអ៊ីចឹងយើងទៅស្នេហាជាមួយខ្មោចស្លាប់មិនប្រសើរជាងឬ ?

ខ្ញុំមានសេចក្ដីឈឺចាប់ នឹងការមើលងាយរបស់អាសត្វតិរច្ឆាននេះឥតអ្វីប្រៀបផ្ទឹមបាន ។ ដោយអានុភាពថ្នាំសណ្ដំដោយអានុភាពនៃការហ៊ឹងត្រចៀក. ដោយអានុភាពនៃកំហឹងខ្ញុំ. ខ្ញុំក៏សន្លប់ភ្លាមមួយរំពេច ឯវិញ្ញាណខ្ញុំក៏ហោះហើរទៅកាន់ពិភពនៃសុបិន ហើយខ្ញុំក៏លែងដឹងអ្វីទៀតឡើយ ...

## ៨

ខ្ញុំឥតបានដឹងថា "មីស្រី" ឧក្រិដ្ឋជនបើកឡានទៅតាមផ្លូវណា រួចនាំខ្ញុំទៅទីណានោះទេ ។ ខ្ញុំនិទ្រាលង់លក់ហាក់បីដូចជាសាកសពដូច្នោះ ។ ដោយសារកម្លាំងចិត្តដែលខ្ញុំខំទប់នឹងអានុភាពថ្នាំអស់កាលដ៏យូរ. ដូច្នេះនៅពេលដែលខ្ញុំចាញ់វា. គឺចាញ់យ៉ាងទ្រុឌទ្រោមបំផុតដែរ ។ ព្រលឹងរបស់ខ្ញុំហាក់បីដូចជាស្ថិតនៅក្នុងភាពងងឹតសូន្យ ដែលគ្មានកោះត្រើយ ។ នៅក្នុងគ្រាដែលខ្ញុំសន្លប់ដោយថ្នាំសណ្ដំនេះ. ព្រលឹងរបស់ខ្ញុំហាក់ដូចជាបានឈរនៅលើកោះតូចមួយ ដែលល្មមតែខ្ញុំម្នាក់ប៉ុណ្ណោះ នាកណ្ដាលសមុទ្រខៀវក្រមៅដ៏ល្វឹងល្វើយនៅជាប់នឹងជើងមេឃ ដែលបោកកព្រោលទៅដោយលលកនិងពពុះ ខ្នូលខ្ញាញ់នៃត្រីឆ្លាមនិងក្រពើសមុទ្រ ។ កាលដែលខ្ញុំកំពុងស្ថិតនៅក្នុង



ការដឹងខ្លួនខ្ញុំមានសេចក្ដីភ័យខ្លាចហួសវិស័យនឹងស្មាន ។ អនិច្ចា ! នៅពេល ដែលខ្ញុំកំពុងនិទ្រាលក់ដោយ សារអានុភាពនៃថ្នាំសណ្ដំនេះ អារម្មណ៍របស់ខ្ញុំក៏គ្មានសេចក្ដីស្ងប់ដែរ. ក្រពើនិងត្រីឆ្លាម. ដែលខ្ញុំជានារីឈរ តែម្នាក់ឯងនៅកណ្ដាលសមុទ្រដ៏មានលក្ខណៈគួរឱ្យរន្ធត់នេះ ។

ពេលវេលាពុំដឹងជាកន្លងទៅប៉ុន្មានម៉ោងនោះទេ ក៏ប៉ុន្តែក្នុងភាពសោះសូន្យសុង ដែលព្រលឹងរបស់ខ្ញុំកំពុងតែអណ្ដែតត្រសែតដោយមហិទ្ធិឫទ្ធិនៃថ្នាំ សណ្ដំនោះស្រាប់តែខ្លួនខ្ញុំបានទទួលនូវការទង្គិចមួយដ៏ខ្លាំង ដោយបណ្ដាលឱ្យខ្ញុំភ្ញាក់បានមួយភ្លែតដែរ ។ គឺហាក់ដូចជាអ្នកណាម្នាក់មកចាប់ខ្ញុំបោះទៅទង្គិចក្បាលនិងជញ្ជាំងមួយ ។ មនសិការរបស់ខ្ញុំបានវិលមកឋានពិភពលោកនេះវិញក្នុងមួយភ្លែតនោះ ហើយត្រចៀករបស់ខ្ញុំហាក់ដូចជាបានឮស្នូរកង់ឡានដែល សង្កៀតនឹងផ្ទៃថ្នល់ដោយការអូស ។ ក្នុងមួយវិនាទីនេះឯងមនសិការនឹងសម្បជញ្ញៈដ៏រាងរៃរបស់ខ្ញុំបានប្រាប់ខ្ញុំឱ្យដឹងថា ខ្ញុំនៅក្នុងរថយន្តពេទ្យនេះនៅឡើយដែលឈប់ដោយបង្ខំចិត្ត ។

នៅក្នុងសភាពអណ្ដែតអណ្ដូងដ៏ល្វើយៗ នេះ. សោតាររបស់ខ្ញុំ

ហាក់ឮសូរស៊ីរ៉ែន ដែលរោទិ៍នៅក្បែរខ្ញុំនេះ ។ ខ្ញុំខំប្រឹងបើកភ្នែក. ក៏ប៉ុន្តែត្របកភ្នែកខ្ញុំពុំព្រមបើកទៅតាមការប្រឹងរបស់ខ្ញុំសោះ ។ ក៏ប៉ុន្តែទោះបីយ៉ាងនេះក្តី ខ្ញុំក៏បានដឹងថា ខ្ញុំបានដេកលង់លក់អស់មួយរយៈកាលហើយ. ហើយបណ្តាលឱ្យខ្ញុំមានកម្លាំងបន្តិចបន្តួចឡើងវិញ ឯថ្នាំសណ្តំក៏រសាយឥទ្ធិពលរបស់វាខ្លះដែរ ។

ក្នុងពេលជាមួយគ្នានោះ ខ្ញុំឮសូរជំហានមនុស្ស ដែលលោតចុះពីរថយន្តស៊ីរ៉ែន ។ ហើយខ្ញុំឮសូរសម្លេងគំហកខ្លាំងរបស់នរណាម្នាក់ ÷

— ខ្ញុំជាតំណាងច្បាប់ ខ្ញុំបានផ្ញើកញ្ចែហៅឡានរបស់លោកឈប់. ហេតុអ្វីបានជាលោកចចេសបើកលឿនពុំព្រមឈប់តាមបញ្ជារបស់ខ្ញុំ?

ក្នុងពេលនោះខ្ញុំឮសម្លេងបុរសម្នាក់តបទៅវិញ ÷

— អត់ទោសលោក ខ្ញុំមិនបានឮ ...

— បើមិនបានឮ.

ហេតុអ្វីបានជាពេលដែលឡានខ្ញុំដេញតាមឡានរបស់ លោក. ម្តេចក៏លោកមិនឈប់ ?

— ខ្ញុំជាបុគ្គលិកពេទ្យ ភារកិច្ចរបស់ខ្ញុំគឺដឹកអ្នកជំងឺយ៉ាងណាឱ្យបានឆាប់រហ័សបំផុត. ករណីយកិច្ចរបស់ខ្ញុំមានតែប៉ុណ្ណឹងទេ ...



ខ្ញុំឮសម្លេងនេះ ខ្ញុំដឹងច្បាស់ថាជាសម្លេងរបស់បុរសថ្មីដែលបានបើកបរឡានជំនួសអាផ្លេកកំពុងតែដេកលក់ស្រមុកឃ្មើយ ដោយថ្នាំ Morphine ដូចខ្ញុំដែរក៏ពុំដឹង ហើយអាមួយថ្មីនេះប្រហែលជាឈ្មោះអាឆ្លូញ. បើតាមសំដីរបស់ឧក្រិដ្ឋជនដែលសន្ទនាជាមួយគ្នា. កាលដែលវាទើបនឹងសែងខ្ញុំចុះពីលើវិមាន បិសាចនោះ ។

ក្នុងពេលនោះឯងខ្ញុំខំប្រមូលកម្លាំងកាយនិងចិត្តទាំងអស់ ដើម្បីនឹងស្រែកអាក្រោសឡើងថា ÷ "មិនមែនទេ ! មិនមែនទេ ! ពួកវាសុទ្ធតែជាឧក្រិដ្ឋជនទាំងអស់ !" ។ ក៏ប៉ុន្តែគ្មានសូរសៀងណាផុះចេញពីប្រអប់មាត់របស់ខ្ញុំឡើយ ព្រោះតាមពិតខ្ញុំមិនអាចហាមាត់ស្រែករួចទេ. មានតែទឹកចិត្តប៉ុណ្ណោះ ក៏ប៉ុន្តែទឹកចិត្តវាស្ថិតនៅក្នុងបេះដូង ហើយបេះដូងវាស្ថិតនៅក្នុងទ្រូង ដែលជិតស្លឹបគ្មានអ្វីបញ្ចេញមកក្រៅសោះ ។

— ខ្ញុំយល់ហើយថាលោកជាពេទ្យ មានភារកិច្ចបំពេញករណីកិច្ចជាពេទ្យ ប៉ុន្តែលោកក៏ជ្រាបដែរថា ខ្ញុំជាប៉ូលីសខ្ញុំក៏មានភារកិច្ចដើម្បីនឹងពិនិត្យតាមពាក្យបណ្តឹងរបស់មនុស្សខ្លះដូច្នោះដែរ ពីព្រោះខ្ញុំអ្វីឡានពេទ្យដែលពុំប្រាកដនោះ ?

ពេលនោះសម្លេង "មីស្រី" ឧក្រិដ្ឋក៏បន្លឺយ៉ាងច្បាស់តបនឹងសំដីរបស់ប៉ូលីស ÷

– លោកមិនឃើញទេឬ ថាពួកខ្ញុំនេះជាពេទ្យ ? មកអាវសនិងឡាន ពេទ្យដែលដឹកអ្នកជំងឺ២នាក់នៅក្នុងនេះ ពុំមែនបញ្ជាក់ថាពួកខ្ញុំជាពេទ្យទេឬ ?

សភាពស្ងប់ក៏កើតឡើងអស់រយៈកាល ៣វិនាទី ។ តាមទំនងមើលភ្នាក់ងារប៉ូលីសប្រហែលជាទាល់ប្រាជ្ញាក៏ពុំដឹង ។ ក៏ប៉ុន្តែនៅក្នុងភាពអស់សង្ឃឹមរបស់ខ្ញុំឮសម្លេងមួយទៀត ដែលជាសម្លេងបុរស សម្លេងនេះពុំអាចបំភ័ន្តខ្ញុំបានទេគឺជាសម្លេងជាទីស្នេហា. គឺជាសម្លេងដ៏ទន់ភ្លន់. គឺជាសម្លេងរបស់បុរស ម្នាក់ដែលខ្ញុំចងចាំជានិច្ច. គឺបងវិចិត្រ ÷

– បើអ្នកស្រីជាពេទ្យមែន. ពួកយើងខ្ញុំក៏មិនជំទាស់អីដែរ ក៏ប៉ុន្តែខ្ញុំសុំមើលមុខអ្នកជម្ងឺផងបានទេ តើអ្នកជម្ងឺនោះជានរណាខ្លះ ? ឈ្មោះអី ?

– លោកដូចជារំលោភពេកហើយ "មីស្រី" ឆ្លើយតប ។ លោកជាប៉ូលីស លោកជាស៊ីវិល. តែលោកពុំមែនជាពេទ្យទេ ហេតុអ្វីក៏



លោកមកចង់រើកកាយក្នុងរឿងរបស់ពេទ្យ ?

– អភ័យទោស. បងវិចិត្របន្ត ។ ខ្ញុំគ្រាន់តែសុំមើលអ្នកជម្ងឺក្រែងខ្ញុំ ស្គាល់ថាអ្នកជម្ងឺនោះគឺជាមនុស្សមួយរូបដែលខ្ញុំបានប្ដឹងប៉ូលីស ហើយដែលខ្ញុំកំពុងតាមរក ។ គឺខ្ញុំពុំមែនពិនិត្យរោគអ្នកជម្ងឺនោះទេ ...

ប្រសិនបើខ្ញុំស្រែករួច. ម្លេះសមខ្ញុំស្រែកឱ្យបែកទ្រូងដើម្បីប្រាប់ថា ÷ "បងវិចិត្រ. អូននៅទីនេះ ! អូននៅទីនេះ ! " ...

ការស្ងប់ស្ងាត់ក៏កើតឡើង ២-៣ វិនាទីទៀត ។ ទីបំផុតសម្លេងខ្ពរៗ របស់ប៉ូលីសក៏បន្លឺឡើង ÷

– យើងខ្ញុំសុំឆែកពិនិត្យមើលអ្នកជម្ងឺក្នុងឡាននេះសិន. ប្រសិនបើពុំមែន ជាអ្នកជម្ងឺដែលទាក់ទងនឹងពាក្យបណ្ដឹងទេ. យើងខ្ញុំនឹងអនុញ្ញាតឱ្យអ្នកស្រីអញ្ជើញទៅភ្លាម ។ សេចក្ដីស្នើសុំក្នុងក្រសួងរបស់ខ្ញុំគឺមិនធ្វើឱ្យអ្នកស្រីខាតពេលហួសពី ៥នាទីឡើយ ...

នៅពេលនោះឯងនៅឯក្រោមជើងរបស់ខ្ញុំ. ខ្ញុំឮសូរនរណាម្នាក់ទាញគន្លាក់ទ្វារយ៉ាងខ្លាំង ។ ហើយក្នុងខណៈពេលតែមួយត្របកភ្នែកដ៏ស្ដើងរបស់ខ្ញុំ ហាក់បានឆ្លុះដល់ដួងកែវនេត្រារបស់ខ្ញុំពន្លឺពិល

ដែលកំពុងជះ ខ្ញុំចង់ស្ទុះក្រោកឡើង ដើម្បីស្រែកអំពាវនាវឱ្យគេជួយខ្ញុំ ។ ក៏ប៉ុន្តែ ខ្ញុំគ្មានកម្លាំងអ្វីសោះ. ក្រៅអំពីភាពមមើមមាយរបស់ខ្ញុំ ។

នៅពេលនោះ ខ្ញុំឮសូរសម្រែកមួយ ÷

— ឱ អូនកន្ទីវ. អូនកន្ទីវ. អូនកន្ទីវរបស់បង!

ហើយក្នុងខណៈតែមួយខ្ញុំឮស្នូរជំហានជើងដែល គេឡើងមកលើរថយន្តនេះ ហើយស្ទុះមកឱបរាងកាយឥតចលនារបស់ខ្ញុំ ។

ពិតហើយនេះគឺជាសម្លេងរបស់បងវិចិត្រ. បងវិចិត្រដែលខ្ញុំស្រឡាញ់រកអ្វីប្រៀបពុំបានក្នុងលោកនេះ ...

តែប៉ុណ្ណេះ. ខ្ញុំបានរួចខ្លួនវិញហើយ ... តែប៉ុណ្ណោះព្រហ្មចារីរបស់ខ្ញុំ មិនត្រូវនរណាក្រៅអំពីបងវិចិត្រហ្វូងហែងខ្ទេចខ្ទីហួរខ្ទុះដូចខ្ទីមដំទេ ឱបអូនឱ្យខ្លាំងមកបងវិចិត្រ ឱបអូនឱ្យណែនមកបងវិចិត្រ ... អូនលែងទៅនរកទៀតហើយ. គឺអូនបានវិលមកឋានសួគ៌ជាមួយនឹងបងវិញ ...

ក្រោយពីបានដឹងថា រាងកាយរបស់ខ្ញុំចាកផុតពីក្រញាំដៃមច្ចុរាជដ៏ឃោរឃៅ. ដ៏យង់ឃ្នង. ដ៏សាហាវ. ដ៏ព្រៃផ្សៃហើយ. ខ្ញុំលែងប្រឹង



ទាំងខាងផ្លូវចិត្តទាំងខាងផ្លូវកាយទៀតហើយ ។ ខ្ញុំបណ្តោយឱ្យអានុភាពថ្នាំលុកទន្ទ្រានខ្ញុំតទៅទៀតចុះ ហើយខ្ញុំក៏ធ្មេចភ្នែកជាថ្មីទៅកាន់ពិភពខ្មៅស្ងួនស្ងាត់ស្ងៀមដើម្បីសម្រាកកាយ ។

បន្ទាប់ពីនោះមកខ្ញុំឥតបានដឹងអ្វីទៀតឡើយ ...

## អវសានបទ

ខ្ញុំបើកនេត្រាសន្សឹមៗ ។ ត្របកភ្នែករបស់ខ្ញុំហាក់ដូចជានៅនឿយសែននឿយនៅឡើយ ... ខ្ញុំប្រទះឃើញរស្មីអារុណោទ័យជះមកលើកញ្ចក់បង្អួចរបស់ខ្ញុំ ។ ក្នុងខណៈតែមួយនោះ ខ្ញុំស្រមៃថាខ្ញុំកំពុងស្ថិតនៅក្នុងវិមានបិសាច. ក្នុងកណ្ដាប់ដៃមច្ចុរាជពីររូប ដែលប្រាថ្នាយកខ្ញុំទៅប្រហារហើយឱ្យខ្ញុំរងទុក្ខវេទនាទាំងរស់នៅជ្រងោ... ពេស្យាកម្ម. ពាក្យនេះស្ត្រីទាំងឡាយក្នុងលោក ខ្ពើមរអើមរកអ្វីប្រៀបពុំបាន ថ្វីត្បិតតែថារបរនេះជារបរមួយប្រចាំសតវត្ស និងប្រចាំសកលលោកនេះក៏ដោយ ។ កើតមកជាស្រីសេចក្ដីប្រាថ្នាដ៏ធំបំផុតរបស់ខ្លួន. គឺពិធីរៀបមង្គលការជាមួយបុរសមួយរូបដែលនាងស្រឡាញ់ ។



ខ្ញុំនឹកស្រមៃសព្វគ្រប់បែបយ៉ាង អំពីសេចក្ដីទុក្ខវេទនាដែលជិះជាន់លើនារីមួយ គ្មាគ្មានអ្វីការពារខ្លួនសោះ ។ ហើយនារីដែលរងគ្រោះនោះគ្មាននរណាក្រៅពីខ្ញុំឡើយ ...

ក្នុងខណៈតែមួយនេះ ស្រាប់តែមនសិការរបស់ខ្ញុំបញ្ជាឱ្យខ្ញុំស្រែកឡើង ថា ÷

– "ទេ ! ទេ ! ខ្ញុំមិនទៅទេ ..."

ម្ដងនេះ ពុំមែនមនសិការរបស់ខ្ញុំទេដែលស្រែក. តាមពិតគឺសម្លេងរបស់ខ្ញុំស្រែកមែនទែនតែម្ដង ហើយរាងកាយរបស់ខ្ញុំក៏ញ័ររញ្ជួយដោយសេចក្ដីភិតភ័យរន្ធត់ឥតឧបមា ។

ក្នុងពេលជាមួយគ្នានោះ រាងកាយរបស់ខ្ញុំបានទទួលនូវការឱបមួយដ៏សែនកក់ក្ដៅ ហើយខ្ញុំឮសម្លេងរបស់បុរសមួយរូបដែលខ្ញុំឥតភ័ន្តច្រឡំសោះ ÷

– កន្និអូន. រាត្រីកាលដ៏ខ្មៅងងឹតបានកន្លងផុតទៅហើយ នៅសល់តែអរុណោទ័យដ៏ទន់ភ្លន់រមណីយ៍ប៉ុណ្ណោះ ... អូននៅក្នុងមន្ទីរពេទ្យ. អូននៅជិតបង ! ពួកឧក្រិដ្ឋជនពួកឃាតករទាំងពីរនាក់នោះបានជាប់អន្ទាក់របស់ប៉ូលីសទៅហើយ ...

តាំងពីមុនមកម្ល៉េះ ថ្វីត្បិតភ្នែកខ្ញុំបើកក្រឡោតក៏ប៉ុន្តែខ្ញុំពុំបានឃើញបងវិចិត្ររបស់ខ្ញុំទេ ។ នេះជាការធម្មតាទេកាលណាសេចក្ដីទុក្ខព្រួយមួយមកញាំញី ... ប៉ុន្តែកាលបើបានឮសម្លេងដ៏ទន់ភ្លន់ត្រជាក់បីដូចទឹកអម្រិតនេះ, ខ្ញុំក៏ភ្ញាក់ស្មារតីជាលើកទី២ ។ ពេលនេះខ្ញុំយល់ច្បាស់ថា កាលពីយប់មិញពេលដែលខ្ញុំហៀបនឹងបណ្ដោយសម្បជញ្ញៈរបស់ខ្ញុំ ឱ្យលិចលង់ក្នុងអានុភាពនៃវេទមន្តថ្នាំសណ្ដំនោះ, ខ្ញុំបានឮសម្លេងបងវិចិត្រ, ខ្ញុំបានឮសម្លេងប៉ូលីស, ដែលគេមកដេញស្កាត់ចាប់រថយន្តពេទ្យ ដែលឧក្រិដ្ឋជនបំរុងដឹកនាំខ្ញុំឆ្លងទៅប្រទេសមួយផ្សេងដើម្បីឱ្យខ្ញុំធ្វើជានារីពេស្យា ...

ខ្ញុំទម្លាក់លំអងក្រសែនេត្រាលើរង្វង់ភក្ត្របងវិចិត្រ ។ គឺបងវិចិត្រមែនពុំមែន "អាប្រុស" ដែលធ្វើទុក្ខបុកម្នេញខ្ញុំ ហើយដែលប្រាថ្នា "ពុះមួយពូថៅឱ្យខ្ញុំដំបៅអស់មួយជីវិត" នោះឡើយ ។

– បងវិចិត្រ ឱបអូនឱ្យតឹងមកបង, កុំឱ្យអូនតក់ស្លុតនិងភ័យខ្លាំងពេក ...

ប្រុសតែប៉ុណ្ណឹងឯង អារឿងដទៃទៀតកុំបញ្ចា, តែបើនិយាយរឿងឱបរិតវិញទុកងារឱ្យចុះ ។ បងវិចិត្រពុំមែនគ្រាន់តែឱបល្មមៗ



នោះទេ គឺគាត់ឱបយកតែមែនទែន ហើយយ៉ាងយូរបំផុត ... ក្នុងខណៈតែមួយនោះឯងខ្ញុំពុំបានដឹងខ្លួនថាខ្ញុំនៅទីណានោះទេ ក៏ប៉ុន្តែខ្ញុំគ្រាន់តែដឹងថាខ្ញុំបានឱបរិតបងវិចិត្រវិញ ហើយខ្លួនខ្ញុំហាក់បីដូចជាអណ្ដែតទៅឋានសួគ៌ឯណោះ ...

យូរណាស់ យូរអើយសែនយូរ ... ទើបខ្ញុំដឹងថាបងវិចិត្រលែងដៃពីប្រាណខ្ញុំគឺលែងនៅពេលដែលទ្វារបន្ទប់បានរបើកឡើង ។ បងស្រីរបស់ខ្ញុំដែលជាមាតាទី២របស់ខ្ញុំ, ស្ទុះចូលមកដោយសេចក្ដីត្រេកអរ ...

– វិចិត្រ, កន្ធីដឹងខ្លួនហើយមែនទេ ?

វិចិត្រក្រហមមុខ ដោយមានការអៀន, ហើយយកដៃភ្ញើយចង្ការបស់ខ្ញុំ ព្រមទាំងជំរាបបងស្រីខ្ញុំថា ÷

– បងស្រី ! កន្ធីដឹងខ្លួនច្បាស់ហើយ, ហើយបានស្រែកហៅខ្ញុំឱ្យ ...

– បងយល់ហើយ ។ បើនៅក្នុងលោកនេះសេចក្ដីស្នេហាផ្ដល់តែទុក្ខសោក ដូចដែលព្រះពុទ្ធទ្រង់សម្ដែងថា "បេមតោជាយតេសោកោ សេចក្ដីលោភទាំងឡាយ កើតមកពីសេចក្ដីស្រឡាញ់មែននោះ" ម្ល៉េះ

សមបក្សាបក្សីទាំងឡាយ ពុំច្រៀងកញ្ច្រៀវខ្សៀវខ្សាសប្បាយនោះទេ![១] ។

បងស្រីខ្ញុំបែរមុខមកញញឹមដាក់ខ្ញុំហើយសួរថា ÷

– អូនស្រួលខ្លួនមែនហើយឬ ?

– ខ្ញុំងក់ក្បាលជាសញ្ញាថា ពិតហើយ ។

♥ ♥

♥

– កន្និរអូន. ហេតុអ្វីបានជាបងហើយនឹងបងស្រីរបស់យើងទៅសង្គ្រោះអូនទាន់ ? ដំណើរនេះមានដូចតទៅ ÷ ពេលក្រោយដែលបងបានដឹងថាអូនទៅមើលកុន រឿងឈឺចិត្តឆ្អិតទ្រូង នៅឯរោងភាពយន្តបូកគោនោះ. ក្រោយពីបង្ហើយផ្ទាំងគំនូររបស់បងហើយ បងក៏ចេញទៅដើម្បីទទួលអូន ហើយឱ្យអូនមានការស្រស់ឡាំងកាំងមួយ ។

[១] Si l'amour ne donnait que de la peine, le soiseaux amoureux ne chanteraient pas tant.



ក៏ប៉ុន្តែអនិច្ចា ! បងពុំឃើញអូនសោះ សូម្បីតែកាលណោះម៉ោងជាង ១១ ទៅហើយក៏ដោយ ។ ក្រៅពីបើករថយន្ត ដោយស្ទើរតែអស់កម្លាំងចិត្តនោះ ស្រាប់តែបងបានឃើញស្រីម្នាក់ដែលស្លៀកពាក់សម្លៀកបំពាក់ពណ៌ក្រហមស្លាទុំ ឈរជាមួយនឹងបុរសស្រ្តីពីររូបទៀតនៅឯក្នុងវិមាន ដែលមានរបងចម្រឹងដែកខ្ពស់ៗ ។ បងមិនចាប់ភ្លឹកថាជាអូននោះទេ ពីព្រោះកាលដែលអូនចេញពីផ្ទះបង អូនស្លៀកពាក់សំពត់អាវពណ៌ខៀវ ...

– ពេលនោះអូនក៏បានឮរថយន្តរបស់បងដែរបងវិចិត្រ ។ សំលេងរថយន្តរបស់បង ទោះបីលាយឡំជាមួយនឹង សម្លេងរថយន្តឯទៀត ១០០គ្រឿងក៏អូនពុំអាចក៏អូនពុំអាចច្រឡំបានដែរ ... ក៏ប៉ុន្តែអនិច្ចា ! ពេលនោះអានុភាពនៃ ថ្នាំសណ្តំវាធ្វើឱ្យអូនទន់ជង្គង់រួចទៅហើយ. អូនស្រែកហៅបងប៉ុន្តែសម្លេង អូនពុំចេញពីបំពង់កសោះ ។

ពេលនោះបងវិចិត្រ ក៏បន្តទៅទៀតថា ÷

– ហើយរថយន្តរបស់បង ក៏បើកហួសច្រក់នោះមក ដោយបងគ្រាន់តែនឹកក្នុងចិត្តថា មានស្រីទី២ម្នាក់ណា រូបរាងដូចអូនតែប៉ុណ្ណោះ ។ ពេលវេលាកន្លងទៅរហូតដល់ទៅ ១២និង៥នាទីយប់.

សេចក្ដីសង្ឃឹមចំពោះការវិលត្រឡប់របស់អូន ក៏រលាយខ្សុរដូចអំបិល ត្រូវទឹក ។ បងដឹងច្បាស់ថាអូនជួប ប្រទះនឹងគ្រោះថ្នាក់មួយ. ហើយគ្រោះថ្នាក់ចំពោះនារីដែលមានរូបឆោមដូចអូននេះ គេទាយ ត្រូវ ១០០០ក្នុង១០០០ភាគ ។ ប៉ុន្តែតើគេត្រូវធ្វើយ៉ាងដូចម្ដេច ។ ដូច្នេះបងត្រូវតែយកការចៃដន្យ ដែលបងបានឃើញស្រីម្នាក់រូបរាង ដូចអូននោះ យកមកអនុវត្តន៍ជាបឋមសិន ។ ប៉ុន្តែអនិច្ចា. នៅពេល ដែលបងនិងបងស្រីយើងបើករថយន្តដើម្បីស្វះស្វែងរកអូន នោះបង ហាក់ដូចជាវង្វេងអស់ហើយ បងរកច្រកផ្លូវដែលបងបានឃើញស្រី ម្នាក់ពីល្ងាចស្លៀកពាក់សំពត់អាវពណ៌ស្វាទុំនោះពុំឃើញសោះ ។ បង ក៏សម្រេចចិត្តឱ្យបងស្រីចូលទៅឯបកប៉ូលីស ដើម្បីជំរាបហេតុការណ៍ ដល់ក្រសួងមានសមត្ថកិច្ច ឱ្យជួយធ្វើអន្តរាគមន៍ឃាត់រថយន្តទាំង អស់ដែលត្រូវចេញពីទីក្រុង ។ ទីបំផុតនៅពេលឡានរបស់បងបត់ បែនតាមផ្លូវគ្រហេងគ្រហូងដ៏ច្រើននោះ ស្រាប់តែបងឃើញឡាន ពេទ្យមួយបើកពីចម្ងាយយ៉ាងលឿន ហើយបត់ចូលតាមផ្លូវឯមុខ មួយនោះ. គំនិតប្រតិកម្មរបស់បងគឺតាមមើលរថយន្តនេះសិន ។ មែនយានគិលានសង្គ្រោះបានបត់ចូលតាមច្រកមួយ. ហើយដែល



ចង្កៀងហ្វារបស់វា បងក៏យល់ច្បាស់ថា គឺជាច្រកដែលកាលពីល្ងាច មិញបងបានឃើញស្រីម្នាក់ស្លៀកពាក់សំពត់អាវពណ៌ស្វាទុំ ។ ការ ដែលច្រឡំមកពីបងរកអូនលើកនេះគឺច្រកនេះត្រូវគេ បិទភ្លើងងងឹត សូន្យ ។ ឡានពេទ្យក្រោយពីបានបត់ចូលទៅដល់ក្នុងហើយ. បង ឃើញស្រីម្នាក់មកបិទទ្វារដែកនេះវិញ. គឺជាស្រីដែលប្រដាប់កាយ ដោយឯកសណ្ឋានពេទ្យ សេចក្ដីសង្ស័យរបស់បងមានប្រសិទ្ធភាព ណាស់ ... ឡានពេទ្យគេពុំដែលបើកមកសម្ងំនៅទីលាននៃវិមានណា មួយនោះទេ ។ បានជាបងសន្និដ្ឋានដូច្នេះ ព្រោះស្ត្រីដែលបានបើកទ្វារ ឱ្យឡាននេះ ចូលហើយបានបិទទ្វារវិមាននេះវិញ ។ បងក៏ចតឡាន នៅកន្លែងងងឹតមួយ ហើយបងរត់សំដៅ ទៅវិមាននោះតាមមធ្យោ-បាយដែលបងសង្ឃឹមថា ម្ចាស់វិមាននោះពុំបានដឹងឡើយ. បងដើរ ឯបខ្លួននឹងរបងចម្រឹងដែកនៅខាងក្រោយវិមាន ។ ពេលវេលាកន្លង ទៅប្រមាណជា ១៥ នាទីក្រោយបងបានឮសូរ សម្លេងមួយយ៉ាង ខ្ទរខ្ទារដែលហែកអាកាសកណ្ដាលរាត្រី "អូយ" ...

— ចាំះ បងវិចិត្រ. គឺពេលនោះហើយអូនជះម្រេចមួយកញ្ចប់ចំ ភ្នែកអាឧក្រិដ្ឋជននោះ ដែលចូលបន្ទប់ប្រាថ្នាបំផ្លាញព្រហ្មចារីអូន ...

ខ្ញុំពោលដោយក្រហមមុខ ។

បងវិចិត្រនៅស្ងៀម. តាំងសំដីអស់មួយរយៈកាល ។ ខ្ញុំក៏ពោលអះអាងឡើងថា ÷ .

– អូនឥតខាតបង់អ្វីសោះ ... សូមបងជឿអូនចុះ !

– កាលណោះ បងចង់ស្ទុះចូលទៅ ក៏ប៉ុន្តែគំនិតប្រតិកម្មទី២ បានឃាត់បងជាប់ ។ ធម្មតាការចាប់បំបាត់មនុស្ស. ឧក្រិដ្ឋជនពុំមែនចាប់មកដើម្បីប្រហារជីវិតភ្លាមនោះទេ ។ គឺដើម្បីធ្វើជាថ្នូរអ្វីមួយ ។ ក៏ប៉ុន្តែប្រសិនបើឧក្រិដ្ឋជនដឹងថាកិច្ចការរបស់ខ្លួនត្រូវបានគេដឹងហើយនោះ. វានឹងសម្លេះជនរងគ្រោះ ដែលខ្លួនបានចាប់មក ។ នេះជាចរិតលក្ខណៈរបស់ឧក្រិដ្ឋជន ។ កាលណោះ គំនិតប្រតិកម្មរបស់បងបំភ្លឺបងថាមិនយូរទេ. ឧក្រិដ្ឋជននឹងនាំអ្នករងគ្រោះ បញ្ចូលក្នុងរថយន្តពេទ្យនេះហើយជាការពិតណាស់ទៅទៀតថា គេមិនដែលនាំ អ្នករងគ្រោះទៅដោយឥតចាក់ថ្នាំសណ្តំទេ ។ មែនដូចការស្មានរបស់បងមែន. បន្តិចក្រោយមកបងក៏ឃើញមនុស្សពីរនាក់ស្រីម្នាក់ប្រុសម្នាក់. បានសែងអ្នកជម្ងឺម្នាក់ចុះមកគ្របដណ្តប់ដោយក្រណាត់ស រួចបញ្ចូលទៅក្នុងឡានពេទ្យ ។ គំនិតប្រតិកម្មទី ៤ របស់បងឥតភ័ន្តច្រឡំ



ឡើយ ។ អ្នករងគ្រោះនេះប្រហែលជា "កន្និ" ។ ហេតុការណ៍មួយធ្វើឱ្យបងឆ្ងល់ គឺថាក្រោយពីបញ្ចូលជនរងគ្រោះ ទៅក្នុងឡានពេទ្យនេះហើយ. ឡាននេះពុំទាន់ចេញភ្លាមនោះទេ ហើយលុះមួយសន្ទុះក្រោយបងឃើញតែស្រីម្នាក់គត់ដែលបើកបរឡាននេះ ។

– បងវិចិត្រ. គឺ "អាប្រុស" នោះវាពុំអាចបើកបរឡានបានព្រោះភ្នែករបស់វាក្រហល់ក្រហាយពើតផ្សា បានដោយសាម្រេចមួយកញ្ចប់ដែលអូនជះចំភ្នែករបស់វា ដូចអាប៉េងគេបើកគ្របចាក់ដូច្នោះវាក៏បញ្ជាឱ្យ "មីស្រី" នោះចាក់ថ្នាំ Morphine មួយម្ជុលដើម្បីឱ្យវាដេកលក់ថ្វីត្បិតតែកម្លាំងកាយរបស់អូនទ្រុឌទ្រោមដោយអានុភាពនៃថ្នាំសណ្តំលើកទីពីរនោះ. មនសិការរបស់អូននៅឃ្លាំប្រុងដើងការណ៍ហើយដឹងហេតុការណ៍ដែលកន្លងទៅទាំងអស់ឥតលោះខាន ។

វិចិត្រក៏បន្តរឿងនេះដូចតទៅ ÷

– ឡានពេទ្យនេះក៏ចេញពីវិមាន ក្រោយពីស្រីអ្នកបើកបរនេះបានបិទទ្វារចម្រឹងដែកនេះវិញ ។ បងដែលបានថយខ្លួនមកប្រុងប្រៀបចាំនៅក្នុងរថយន្តរបស់បងស្រេចហើយនោះ. បងក៏ដេញតាមឡាននេះដោយមិនឱ្យដឹងខ្លួនហើយនិងមិនឱ្យបាត់ដានឡើយ ។ បន្ទាប់មក

ឡាននេះក៏ឈប់នៅមុខផ្ទះមួយទៀត. ស្រីនោះក៏ឡើងទៅលើផ្ទះនោះ. បីនាទីក្រោយមកបុរសម្នាក់ទៀត ដែលមានឯកសណ្ឋានជាពេទ្យដែរ ក៏ឡើងមកបើកបរឡាននេះជំនួសនាង ។ ទីបំផុតយានគិលានសង្គ្រោះនេះ ក៏ចេញដំណើរឆ្ពោះទៅផ្លូវដែលទៅគីឡូម៉ែត្រលេខ ៦ ។ ប៉ុន្តែជាភ័ព្វសំណាងហើយអាស្រ័យដោយមនសិការរបស់ប៉ូលីសផងនោះ បងឃើញគេឆែកឆេរគ្រប់ផ្លូវចេញទាំងអស់ ហើយនៅឯជិតផ្សារថ្មី បងឃើញឡានប៉ូលីសមួយដែលយាមនៅទីនោះប្រចាំការ ។ បងធ្វើសញ្ញាដៃហើយចង្អុលឡានពេទ្យ ។ ទំនងជាបានដឹងភេរវសញ្ញានេះជាមុនឡានប៉ូលីស ក៏បានបំពេញករណីកិច្ចរបស់ខ្លួនគួរឱ្យសរសើរ ។ បន្ទាប់ពីនោះមកអូនក៏បានដឹងសព្វគ្រប់អស់ហើយ. មិនថាអ៊ុំចឹង ... ។

ចប់

ម៉ោងឫស្សី ១០ កក្កដា ១៩៦៩